**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១០ .សរណន

## សារាចរណែនាំ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជួយសម្របសម្រួលការគ្រប់គ្រងរោងចក្រ សហគ្រាសដែលស្ថិតក្នុងភូមិសាស្ត្ររាជធានី ខេត្ត

រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ការអភិវឌ្ឍសេដ្ឋកិច្ចជាតិមានការរីកចម្រើនយ៉ាងឆាប់រហ័ស ក្នុងនោះវិស័យកម្មន្តសាលមានការអភិវឌ្ឍយ៉ាងលឿន ហើយមានគ្រឹះស្ថានផលិតកម្ម សេវាកម្មជាច្រើនត្រូវបានបង្កើតឡើង ផ្តល់ការងារធ្វើរាប់លានដល់ប្រជាពលរដ្ឋ។ រោងចក្រសហគ្រាស ជាច្រើនត្រូវបានបង្កើតឡើងនៅតាមរាជធានី ខេត្ត ដែលមានទីតាំងពីទីក្រុង ទីប្រជុំជន រហូតដល់តំបន់ជនបទ។

រដ្ឋបាលថ្នាក់ក្រោមជាតិ បានយកចិត្តទុកដាក់បង្កលក្ខណៈងាយស្រួលដល់រោងចក្រសហគ្រាស ក្នុងដំណើរការផលិតកម្មអាជីវកម្មរបស់ខ្លួន បានល្អស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

និយោជកតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន បានគោរព និងអនុវត្តច្បាប់ លិខិតបទដ្ឋានជាធរមាន និងមានទំនាក់ទំនងល្អជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដើម្បីបន្តពង្រឹងការអភិវឌ្ឍវិស័យកម្មន្តសាល ឲ្យមានការរីកចម្រើនលូតលាស់ទៅគ្រប់រាជធានី ខេត្ត សំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងដោះស្រាយការងារជូនប្រជាពលរដ្ឋនៅជិតលំនៅឋានបានល្អប្រសើរ រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជួយសម្របសម្រួលការគ្រប់គ្រងរោងចក្រ សហគ្រាសដែលស្ថិតក្នុងភូមិសាស្ត្ររាជធានី ខេត្ត ដូចតទៅ៖

១-អភិបាលរាជធានី ខេត្ត ត្រូវបន្តបង្កលក្ខណៈងាយស្រួល និងជួយឧបត្ថម្ភគាំទ្រដល់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងដំណើរការផលិតកម្ម អាជីវកម្ម ដែលស្ថិតនៅភូមិសាស្ត្ររបស់ខ្លួនឲ្យបានល្អ។

២-អភិបាលរាជធានី ខេត្ត មានសិទ្ធិអញ្ជើញនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ផលិតកម្ម អាជីវកម្ម ដែលស្ថិតនៅភូមិសាស្ត្ររបស់ខ្លួន ដើម្បីពិភាក្សាការងារដែលពាក់ព័ន្ធនឹងសមត្ថកិច្ច។ ។/

៣-អភិបាលរាជធានី ខេត្ត ដោយមានមន្ទីរជំនាញជាសេនាធិការ អាចធ្វើអធិការកិច្ច តាមការចាំបាច់ចំពោះរោងចក្រ សហគ្រាស គ្រឹះស្ថាន ផលិតកម្ម អាជីវកម្ម និងចាត់វិធានការតាមច្បាប់ជាធរមាន។

៤-នាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ផលិតកម្ម អាជីវកម្ម ត្រូវមានទំនាក់ទំនងសហការឲ្យបានល្អជាមួយអភិបាលរាជធានី ខេត្ត និងអាជ្ញាធរដែនដីដែលរោងចក្រ សហគ្រាស គ្រឹះស្ថានផលិតកម្ម អាជីវកម្ម បោះទីតាំង។

៥-ក្នុងករណីមានវិវាទការងារកូដកម្ម បាតុកម្ម អភិបាលរាជធានី ខេត្ត និងជាប្រធានគ.ក.ប. រាជធានី ខេត្ត ត្រូវចាត់វិធានការដោះស្រាយតាមបទប្បញ្ញត្តិជាធរមាន ជាពិសេសតាមបទបញ្ជាលេខ ០៣ បប ស្តីពីការរក្សាការពារ សន្តិសុខ សណ្តាប់ធ្នាប់ សាធារណៈ នៅតាមតំបន់រោងចក្រសហគ្រាស និងតំបន់ឧស្សាហកម្ម។

គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវអនុវត្តសារាចរណែនាំនេះឲ្យមានប្រសិទ្ធភាព ៕

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ[illegible] ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ១ ប្រការ ២
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ